# តើលោកអ្នកកំពុងទទួល Newstart Allowance (ប្រាក់ជំនួយ Newstart) និងកំពុងធ្វើការឬទេ?



We speak your language ☎ 13 1202

*Are you receiving Newstart Allowance and working?* - **Khmer**

ដើម្បីគណនាចំនួនប្រាក់ Newstart Allowance ដែលយើងខ្ញុំអាចបើកជូនលោកអ្នក  យើងខ្ញុំត្រូវដឹងអំពីពេលដែលស្ថានការណ៍របស់លោកអ្នកផ្លាស់ប្តូរ។

សូមចងចាំក្នុងការ:

- ប្រាប់យើងខ្ញុំ បើលោកអ្នកឬគូរួមមេត្រីភាពរបស់លោកអ្នកចាប់ផ្តើមធ្វើការ
- ប្រាប់យើងខ្ញុំនូវប្រាក់ចំណូលដែលលោកអ្នកទទួលសំរាប់ថ្ងៃទាំងអស់ដែលលោកអ្នកបានធ្វើការ ទោះជាលោកអ្នកមិនទាន់បានទទួលប្រាក់ចំណូលនេះក៏ដោយ
- ប្រាប់យើងខ្ញុំនូវចំនួនម៉ោងដែលលោកអ្នកបានធ្វើការ
- ប្រាប់យើងខ្ញុំនូវ**ប្រាក់ចំណូលមិនទាន់បង់ពន្ធ**។ នេះគឺជាចំនួនប្រាក់នៅមុនពេលបង់ពន្ធនិងចំនួនកាត់យកចេញផ្សេងៗទៀត
- ទាក់ទងយើងខ្ញុំភ្លាម តាមទូរស័ព្ទលេខ **13 1202** បើលោកអ្នកដាក់ក្រដាសបំពេញរបស់លោកអ្នកនៅ រៀងរាល់ពេល 4, 6, 8, 10 ឬ 12 អាទិត្យម្តង ហើយលោកអ្នកទទួលប្រាក់ចំណូលណាមួយ
- សុំឲ្យនិយោជកលោកអ្នកប្រាប់អំពីអត្រាប្រាក់បើកប្រចាំម៉ោងរបស់លោកអ្នក ដោយមានរួមទាំងអត្រាប្រាក់បើកសំរាប់ថ្ងៃចុងអាទិត្យឬថ្ងៃឈប់សំរាក ឬអត្រាប្រាក់បើកសំរាប់ពេលលើសម៉ោងធ្វើការធម្មតា ហើយនិងប្រាក់ឧបត្ថម្ភ
- ភ្ជាប់ប័ណ្ណជូនដំណឹងអំពីប្រាក់ចំណូលរបស់លោកអ្នក ជាមួយនឹងក្រដាសបំពេញរៀងរាល់ពេលពីរអាទិត្យម្តងរបស់លោកអ្នក
- ប្រាប់យើងខ្ញុំនូវប្រាក់ចំណូលពីនិយោជកនីមួយៗ បើលោកអ្នកឬគូរួមមេត្រីភាពរបស់លោកអ្នកមាននិយោជកច្រើនជាងម្នាក់។
  - សុំយក Casual Income Record (បញ្ជីកត់ត្រាប្រាក់ចំណូលម្តងម្កាល) ពីការិយាល័យ Centrelink ណាមួយក៏បានដែរ។ បញ្ជីកត់ត្រានេះ អាចជួយលោកអ្នកក្នុងការកត់ត្រាប្រាក់ចំណូលរបស់លោកអ្នក
- សួរយើងខ្ញុំអំពីការផ្លាស់ប្តូរថ្ងៃខែដែលលោកអ្នកប្រគល់ក្រដាសបំពេញលោកអ្នកមកឲ្យយើងខ្ញុំវិញ ដើម្បីឲ្យត្រូវគ្នានឹងថ្ងៃដែលនិយោជកបើកប្រាក់ជូនលោកអ្នក។

បើលោកអ្នកឬគូរួមមេត្រីភាពរបស់លោកអ្នកមិនប្រាប់យើងខ្ញុំនូវការផ្លាស់ប្តូរណាមួយដូចដែលតំរូវឡើងទេនោះ វាអាចបណ្តាលឲ្យ:

- យើងខ្ញុំបញ្ឈប់ឬពន្យារពេលបើកប្រាក់ជូនលោកអ្នក **ហើយ/ឬ**
- លោកអ្នកអាចត្រូវបង់សងមកវិញនូវប្រាក់បើកលើស **ហើយ/ឬ**
- លោកអ្នកត្រូវបង់ថ្លៃឈ្នួលសំរាប់ការទារសំណងប្រាក់លើសមកវិញ នៅក្នុងករណីខ្លះ។

បើលោកអ្នកកំពុងអនុវត្តតាមតេស្តសកម្មភាពរបស់លោកអ្នកតាមរយៈការធ្វើការងារ ហើយចំនួនម៉ោងធ្វើការរបស់ លោកអ្នកបានធ្លាក់ចុះមកនៅតិចជាង 30 ម៉ោងនៅក្នុងពេលពីរអាទិត្យនោះ លោកអ្នកត្រូវប្រាប់ Centrelink ភ្លាម។

ដើម្បីនិយាយទៅកាន់ Centrelink ជាភាសាខ្មែរ សូមទូរស័ព្ទទៅលេខ **13 1202*** ។
លោកអ្នកក៏អាចរកឃើញព័ត៌មានជាភាសាលោកអ្នក នៅតាមវ៉ិបសៃ **www.centrelink.gov.au** ផងដែរ។

** លោកអ្នកអាចប្រើកិច្ចបំរើទូរស័ព្ទស្តង់ដារនៅគ្រប់ទីកន្លែងទាំងអស់ក្នុងរង្វង់ប្រទេសអូស្ត្រាលីដើម្បីទូរស័ព្ទទៅកាន់លេខចាប់ផ្តើមដោយលេខ "13" ដោយបង់ថ្លៃមិនលើសពីថ្លៃទូរស័ព្ទក្នុងតំបន់ឡើយ (ថ្លៃទូរស័ព្ទអាចមានតម្លៃខុសៗគ្នា ដោយអាស្រ័យលើក្រុមហ៊ុនផ្តល់កិច្ចបំរើទូរស័ព្ទ)។ ទូរស័ព្ទទៅលេខចាប់ផ្តើមដោយលេខ "1800" ឥតមានគិតថ្លៃទេ។ ទូរស័ព្ទចេញពីទូរស័ព្ទសាធារណៈដែលត្រូវបង់ប្រាក់ ទូរស័ព្ទចល័ត និងត្រូវបង់ថ្លៃតាមអត្រាខ្ពស់ជាងនោះ។*

www.centrelink.gov.au

Australian Government

Centrelink
giving you options

MCLW025KHM.0608 (page 1 of 1)